# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ACCOUNTING AND AUDITING REGULATOR

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ...០៥៦.......ន. គ. ស/សណ.ស.ណា.

ថ្ងៃសុក្រ ១៥កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០២២

## សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២១ តាមប្រព័ន្ធអនឡាញ សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ មកនិយ័តករគណនេយ្យនិងសវនកម្ម

យោងតាមសេចក្តីណែនាំលេខ ០១០ ន.គ.ស. ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ ស្តីពីការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រង់ចំណុច (២) ចែងថា "**អង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមកនិយ័តករគណនេយ្យនិងសវនកម្ម**" អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។ ដើម្បីជំរុញការដាក់ឱ្យអនុវត្តកាតព្វកិច្ចនេះមានប្រសិទ្ធភាពខ្ពស់ **និយ័តករគណនេយ្យនិងសវនកម្ម(ន.គ.ស.)**មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ហៅកាត់ថា "**អង្គភាព**" ទាំងអស់មេត្តាជ្រាបថា÷ **ន.គ.ស.** បានបើកឱ្យដំណើរការមុខងារដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទ ២០២១ តាមប្រព័ន្ធអនឡាញ (E-Filing for NFPEs)។ "**អង្គភាព**" ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** តាមពេលវេលាដែលបានកំណត់ដូចខាងក្រោម÷

*១.**អង្គភាពមិនរងសវនកម្មឯករាជ្យ÷*** *ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** ឱ្យបានមុនថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២។*

*២.**អង្គភាពរងសវនកម្មឯករាជ្យ÷*** *ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** ឱ្យបានមុនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ។*

បែបបទ និងនីតិវិធីនៃការដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុ ត្រូវអនុវត្តតាមសេចក្តីណែនាំលេខ ០៤២ ន.គ.ស/ស.ណ.ន ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមន្ត្រីនៃ **ន.គ.ស.** តាមរយៈលេខទូរស័ព្ទ និងតេឡេក្រាម÷ ០៨៥ ៩០៤ ៨៤៨/០៨៥ ៤៤៤ ៤៨៨/០៨១ ៦៤៤ ៦៦៣/០៨៩ ៥០៨ ៥៦៧។

"**ការខកខាន ឬការយឺតយ៉ាវមិនបានអនុវត្តកាតព្វកិច្ចតាមការកំណត់ខាងលើ អង្គភាពត្រូវរងទោសទណ្ឌដូចមានចែងក្នុងអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម**"។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អង្គភាពមិនស្វែងរកប្រាក់ចំណេញ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តតាមសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**អគ្គនាយក**

**ប៊ិ ថារិន**

**ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សូមចូលរួមក្នុង Telegram Channel របស់និយ័តករគណនេយ្យនិងសវនកម្ម**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០២៣ ៨៨២ ១១១
Phone: 023 882 111